17-Sep-15 1

# ដំណើរការអនុវត្ត ផ្ទេរមុខងារឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៥

17-Sep-15 2

## មាតិកាបទបង្ហាញ

1. ក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
2. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)
3. ភាពចាំបាច់នៃការផ្ទេរមុខងារ
4. លទ្ធផលសម្រេចបាន (ក្រុម D&D)
5. ការសាកល្បងផ្ទេរមុខងារនៅខេត្តបាត់ដំបង
   - ប្រកាសស្ដីពីការសាកល្បងផ្ទេរមុខងារ
   - សៀវភៅណែនាំស្ដីពីការអនុវត្តសាកល្បងមុខងារ

## 1. ក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តគោលនយោបាយ អភិបាលកិច្ចល្អដោយដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ កាលពីឆ្នាំ២០០៤ ក្នុងនោះរួមមានកម្មវិធីកំណែទម្រង់រដ្ឋបាលសំខាន់ៗចំនួន ៤ គឺ៖
  - ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
  - កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
  - **កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ**
  - កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសកម្មវិធីកាត់រំសាយទ័ព

- នៅខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈកា សំដៅបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាននិងកាត់បន្ថយភាពក្រីក្រ ។



## ច្បាប់រៀបចំអង្គការ

## ក. ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- មាត្រា ២១៥ មាត្រា ២១៦ មាត្រា ២១៧ មាត្រា ២១៨ មាត្រា ២១៩ មាត្រា ២២០ និង មាត្រា ២២១៖ ការពិនិត្យមើលមុខងារឡើងវិញដើម្បីកំណត់ពីមុខងារណាខ្លះដែលត្រូវផ្ទេរទៅឲ្យរដ្ឋបាលរាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ និង មុខងារណាខ្លះដែលត្រូវរក្សាទុកនៅថ្នាក់ជាតិ។ មុខងារអាទិភាព៖
  - កសិកម្ម
  - អប់រំ
  - ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
  - សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រីបុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច

- ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដី
- ការងារសុរិយោដី និងការងារសំណង់
- ការផលិត និងចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- តម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ
- **សង្គមកិច្ច និង**
- អភិវឌ្ឍន៍ជនបទ

- មាត្រា ២៣៣ មាត្រា ២៣៤ មាត្រា ២៣៥ មាត្រា ២៣៦ មាត្រា ២៣៧ មាត្រា ២៣៨ មាត្រា ២៣៩ និង មាត្រា ២៤០ ៖ដំណើរការផ្ទេរមុខងារ ជាកាតព្វកិច្ច ឬជាជម្រើស តាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម និងការផ្ទេរធនធាន ពីក្រសួង ស្ថាប័ននានា ទៅឲ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។



## ខ. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

- មាត្រា ៤៤ ៖ "ការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋទៅឲ្យរដ្ឋបាលឃុំសង្កាត់ ដោយមានភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងការផ្តត់ផ្គង់មធ្យោបាយ  សម្ភារៈ និងថវិកាសម្រាប់អនុវត្ត។"

17-Sep-15 7

## រចនាសម្ព័ន្ធក្របខ័ណ្ឌគតិយុត្ត




17-Sep-15 8

## 2. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)

- មានគោលបំណងលើកកម្ពស់បរិមាណ និងគុណភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការផ្ទេរមុខងារឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ។
- ធានាថា ការផ្ទេរមុខងាររួមទាំងការផ្ទេរធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវ ត្រូវបានធ្វើឡើងដោយមានភាពជាដៃគូជាមួយក្រសួង ស្ថាប័ន ព្រមទាំងផ្អែកលើវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលា។

ក. លទ្ធផលអនុវត្ត ផអ៣.១ (២០១១-២០១៣+២០១៤)

ផអ៣ ទី១. បានបង្កើតនូវមូលដ្ឋានគ្រឹះចាំបាច់នានាសម្រាប់កិច្ចប្រតិបត្តិការរបស់រដ្ឋថ្នាក់ក្រោមជាតិដូចជាការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធីអនុវត្តការងារ និងការអភិវឌ្ឍសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រសួងស្ថាប័នមួយចំនួនបានរៀបចំ និងបញ្ចប់បញ្ជីវិភាគមុខងារ និងការពិនិត្យមើលមុខងារឡើងវិញ



ខ. ផអ៣.ទី២ (២០១៥-២០១៧)

ផអ៣ទី២ នឹងផ្តោតទៅលើការជំរុញ និងពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឲ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវលើកកម្ពស់ការអនុវត្តមុខងារជាជម្រើសក្នុងក្របខណ្ឌនៃអាណត្តិទូទៅ និងមុខងារជាកាតព្វកិច្ចដែលបានផ្ទេរមកឲ្យពីក្រសួង ស្ថាបននានា។

17-Sep-15 11

# វាក្យសព្ទ

- **វិមជ្ឈការ:** មានន័យថា រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យ សម្បត្តិ និងបុគ្គលិក)ឲ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន
- **វិសហមជ្ឈការ:** មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅអង្គភាពក្រោមបង្គាប់ ឬទៅ ក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះក្នុងនាម រាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ

17-Sep-15 12

- **តួនាទី** (Role) សំដៅទៅលើសំណុំសកម្មភាពដែលផ្តល់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តឲ្យបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃស្ថាប័ន អង្គភាព ឬរដ្ឋបាលថ្នាក់ក្រោមជាតិ
- **ភារកិច្ច** (Duty) សំដៅទៅលើកិច្ចការនានាដែលបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃស្ថាប័ន អង្គភាព ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចត្រូវអនុវត្ត ។
- **មុខងារ (Function)** សំដៅទៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈទង្វើប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។

- **មុខងារជាកាតព្វកិច្ច (Obligatory Functions)** គឺជាមុខងារដែលផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬច្រើនដែលបានកំណត់ដោយក្រសួង ឬស្ថាប័នថ្នាក់ជាតិ ។
- **មុខងារជាជម្រើស (Permissive Function)** គឺមុខងារដែលរដ្ឋបាលថ្នាក់ក្រោមជាតិមាន **ឆន្ទានុសិទ្ធិ** ក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែន សមត្ថកិច្ចរបស់ខ្លួនដោយមិនមានការរំលោភ ឬផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ជាតិ។



- **ការផ្ទេរមុខងារ (Transfer of Function)** សំដៅទៅលើការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារទៅឲ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវធនធាន និងសមត្ថភាព ។
- **ការទទួលខុសត្រូវ (Responsibility)**សំដៅទៅលើតួនាទី និងកាតព្វកិច្ចដែលបានប្រគល់ឲ្យដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តទៅឲ្យបុគ្គល អង្គការចាត់តាំងនៃរដ្ឋបាលណាមួយ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-national Authority)** គឺជានីតិបុគ្គល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ដែលមានក្រុមប្រឹក្សារបស់ខ្លួននីមួយៗ ជាតំណាងដូចមានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ។

- **សិទ្ធិអំណាច (Authority)** សំដៅទៅលើលទ្ធភាពតាមផ្លូវច្បាប់ក្នុងការអនុវត្ត នូវការទទួលខុសត្រូវដែលផ្ទេរទៅឲ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- **មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ (Unconditional Fund)** គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បីៈ
  - –បំពេញភារកិច្ចតាមផ្លូវច្បាប់
  - –បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
  - –ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន
  - –ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា



- **មូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ** (Conditional Fund) គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់:
  - –ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វមួយ ឬច្រើនដែលត្រូវបានផ្ទេរឲ្យក្រុមប្រឹក្សាតាមការប្រគល់មុខងារ ឬការធ្វើ ប្រតិភូកម្មមុខងារ ។
  - –ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ។
  - –សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬច្រើនដែលបានកំណត់

## 3. ភាពចាំបាច់នៃការផ្ទេរមុខងារ

- បង្វិតសេវាឲ្យទៅជិតកៀកប្រជាពលរដ្ឋ កែលម្អគុណភាពការផ្ដល់សេវាដល់ប្រជាពលរដ្ឋ មានតម្លាភាព និងគណនេយ្យភាព ព្រមទាំងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ការផ្ទេរមុខងារ និងធនធានឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាលមានសន្និទានភាព មានលក្ខណៈជាប្រព័ន្ធ មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានផែនការ មានតម្លាភាព និង ប្រកបដោយសមធម៌

សន្និទានភាព: មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានផែនការ មានតម្លាភាព និងជាអចិន្ត្រៃយ៍



- ការផ្ទេរមុខងារតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖
  - ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
  - អាចគ្រប់គ្រង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនៅក្នុងដែលសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
  - បម្រើ ឬផ្ដល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែលសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
  - មានផលប៉ះពាល់ជាចម្បងនៅក្នុងដែលសមត្ថកិច្ចរបស់ក្រុមប្រឹក្សា

17-Sep-15 19

- ការផ្ទេរមុខងារតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងធានាថា៖
  - –ការផ្ទេរមុខងារត្រូវផ្សាភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់ និងសមស្រប
  - –មានតម្លាភាព មានការពិគ្រោះយោបល់ និងមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងតំណាងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលមុខងារ ដោយមានការសម្រប សម្រួលពី គណៈកម្មាធិការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប អនុគណៈកម្មាធិការមុខងារនិងធនធាន និង លេខាធិការដ្ឋាន គ.ជ.អ.ប
  - –មានការរំខានជាអប្បរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល

17-Sep-15 20

4. **លទ្ធផលសម្រេចបាន** (**ក្រុម** D&D)

នៅខែឧសភា ឆ្នាំ២០០៩ ក្រសួង ស.អ.យ បានបង្កើតក្រុមការងារវិមជ្ឈការ និង វិសមជ្ឈការ ដែលមានភារកិច្ចរបស់ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការរួមមាន៖

- សិក្សា និងពិនិត្យឡើងវិញនូវមុខងារនានារបស់ក្រសួង និងធ្វើការវិភាគនូវជម្រើសនានាអំពីមុខងារនាពេលអនាគតសម្រាប់កម្រិតថ្នាក់ក្រោមជាតិ
- រៀបចំនីតិវិធី និងទំនាក់ទំនងជាក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ក្នុងការផ្ទេរមុខងារដែលក្រសួងបានកំណត់ផ្ទេរ ឬធ្វើប្រតិភូកម្ម ទៅឲ្យថ្នាក់ក្រោមជាតិ តាមគោលការណ៍ និងផែនការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

17-Sep-15 21

លទ្ធផល៖

- នៅឆ្នាំ២០១០ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការបានធ្វើការសិក្សានៅថ្នាក់ជាតិ និងខេត្តចំនួន ដើម្បីរៀបចំរបាយការណ៍បឋមស្តីពីការពិនិត្យឡើងវិញនូវមុខងារ
- អនុវត្តតាមអនុក្រឹត្យ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងពិនិត្យមើលមុខងារឡើងវិញ ក្រសួងបានបញ្ចប់៖

  ក. របាយការណ៍ការរៀបចំបញ្ជីវិភាគមុខងារ

  ខ. របាយការណ៍ពិនិត្យមើលមុខងារឡើងវិញ

17-Sep-15 22

ក. ការរៀបចំបញ្ជីវិភាគមុខងារ

- រៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ស្តីពីដំណើរការរៀបចំបញ្ជីវិភាគមុខងារដោយផ្តោតលើនាយកដ្ឋានជំនាញទាំងអស់នៃទីស្តីការក្រសួងដោយមានអ្នកចូលរួម ៩៦នាក់។
- ក្រុមការងារ ចុះប្រជុំពិគ្រោះយោបល់នៅថ្នាក់ក្រោមជាតិគ្រប់ខេត្តដែលមានអ្នកចូលរួមចំនួន៩៦៩នាក់ ក្នុងនោះមានស្ត្រី ២៣៩នាក់ (មន្ត្រីមន្ទីរ ការិយាល័យ ស.អ.យ ៧៩៣នាក់ និងក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ១៧៦នាក់) ។


17-Sep-15
23


17-Sep-15
24

## លទ្ធផលសង្ខេបនៃការរៀបចំបញ្ជីវិភាគមុខងារ និងធនធាន

### ក. មុខងារ និងមុខងាររង (១៩៧)

- មុខងារ ចំនួន ៤១
- មុខងាររង ចំនួន ១៥៦

### ខ. ធនធាន

ខ១.មន្ត្រីរាជការ (១.៥៥១នាក់)

- មន្ត្រីរាជការថ្នាក់ជាតិ ៥៣៤ នាក់
- មន្ត្រីរាជការថ្នាក់មន្ទីរ ៦៧៨ នាក់
- មន្ត្រីរាជការថ្នាក់ការិយាល័យ ស្រុក ៣៣៩ នាក់

ខ២.ថវិកា (៥៩.៤ លានដុល្លា +)

- ថវិកាថ្នាក់ក្រសួង ៥.៤ លានដុល្លា/១ឆ្នាំ (មធ្យម)
- ថវិកាថ្នាក់មន្ទីរ (៥៤ លានដុល្លា/១ឆ្នាំ(មធ្យម)



## ខ. ការពិនិត្យមើលមុខងារឡើងវិញ

- ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការបានធ្វើការចុះជួបប្រជុំពិគ្រោះយោបល់ និងប្រមូលព័ត៌មានទាក់ទងនឹងការផ្តល់សេវាសុខុមាលភាពសង្គមនៅតាមមូលដ្ឋាននៃកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។
- ក្រុមការងារបានជួបប្រជុំពិភាក្សាដោយផ្ទាល់ជាមួយ ក្រុមប្រឹក្សាគណៈអភិបាលខេត្ត និងអ្នករពាក់ព័ន្ធមកពី(មន្ទីរ ស.អ.យ មន្ទីរកិច្ចការនារី មន្ទីរអប់រំ មន្ទីរសុខាភិបាល និងអង្គការដៃគូ) ក្រុមប្រឹក្សាគណៈអភិបាលស្រុក អ្នកពាក់ព័ន្ធមកពី(ការិយាល័យ ស.អ.យ កិច្ចការនារី អប់រំ សុខាភិបាលនិងអង្គការដៃគូ) និងក្រុមប្រឹក្សាឃុំ/សង្កាត់ បាត់ដំបង កំពង់ចាម និងខេត្តកំពត ព្រៃវែង និងស្វាយរៀង

## លទ្ធផលសង្ខេបនៃការពិនិត្យមើលមុខងារឡើងវិញ

### ក. មុខងារ និងមុខងាររង (១៩៧)

- មុខងារស្នើឡើង ១៦ ដើម្បីផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារមួយចំនួនកំពុងតែអនុវត្តដោយ មន្ទីរ ស.អ.យ និង រដ្ឋបាលថ្នាក់ក្រោមជាតិ

### ខ. ធនធាន

- ក្រសួងមិនមានថវិកាគាំទ្រទាំងស្រុងលើការអនុវត្តមុខងារទាំងនេះទេ៖ ថ្នាក់ក្រសួង និងថ្នាក់ក្រោមជាតិ (ប្រាក់ខែ ប្រាក់មុខសញ្ញា បេសកម្ម និងទិវា)
- បច្ចុប្បន្នការផ្តល់សេវាសង្គមមួយចំនួនធំអនុវត្តដោយអង្គការដៃគូ
- ធនធានមនុស្សទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនូវមានកម្រិតមិនអាចឆ្លើយតបទៅនឹងតម្រូវការសេវាសង្គមកិច្ច (មន្ត្រីម្នាក់ទទួលអនុវត្តមុខងារច្រើន)



## មុខងារស្នើឡើងដើម្បីផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ | រដ្ឋបាលថ្នាក់ក្រោមជាតិ | ប្រគល់ | ប្រតិភូកម្ម | កាតព្វកិច្ច | ជម្រើស |
|---|---|---|---|---|---|---|
| ១ | ផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនរងគ្រោះ និងងាយរងគ្រោះដោយដោយដាច់ស្បៀង ទីទ័លក្រ រងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ | ឃុំ សង្កាត់ | X | | X | |
| ២ | ស្រង់ទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះ | ឃុំ សង្កាត់ | X | | X | |
| ៣ | ផ្តល់សេវាថែទាំកុមារកំព្រានិងកុមារងាយរងគ្រោះនៅក្នុងមណ្ឌល(រដ្ឋ&NGOs) | រាជធានី ខេត្ត | X | | X | |
| ៤ | ផ្តល់សេវាថែទាំកុមារកំព្រានិងកុមារងាយរងគ្រោះនៅក្នុងគ្រួសារនិងសហគមន៍(NGO) | ឃុំ សង្កាត់ | X | | X | |
| ៥ | ផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា | ក្រុង ស្រុក ខណ្ឌ | | X | | X |
| ៦ | ប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ | រាជធានី ខេត្ត | | X | | X |
| ៧ | ស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការនៅក្នុងមណ្ឌល និងតាមសហគមន៍ | រាជធានី ខេត្ត | | X | | X |
| ៨ | ជួយរៀបចំ និងបណ្តុះបណ្តាលក្រុមជួយខ្លួនឯងនៃជនពិការ | រាជធានី ខេត្ត | | X | | X |
| ៩ | ទប់ស្កាត់ និងការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ | ក្រុង ស្រុក ខណ្ឌ | | X | | X |
| ១០ | ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជនដែលប្រព្រឹត្តល្មើស | រាជធានី ខេត្ត | | X | | X |
| ១១ | ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មយុវជន និងកុមារដែលបានប្រើប្រាស់គ្រឿងញៀន | រាជធានី ខេត្ត | | X | | X |
| ១២ | អភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ | រាជធានី ខេត្ត | X | | X | |
| ១៣ | ថែទាំមនុស្សចាស់តាមគ្រួសារ និងសហគមន៍ | រាជធានី ខេត្ត | | X | | X |
| ១៤ | ជម្រុញការអនុវត្ត និងពង្រឹងពង្រីកគម្រោងអភិវឌ្ឍអតីតយុទ្ធជននៅថ្នាក់ឃុំសង្កាត់ | ឃុំ សង្កាត់ | X | | X | |
| ១៥ | ទទួលពាក្យសុំសម្បទានដីសង្គមកិច្ច និងសង់ផ្ទះជូនអតីតយុទ្ធជន | រាជធានី ខេត្ត | | X | | X |
| ១៦ | ចុះកិច្ចព្រមព្រៀងគម្រោងជាមួយអង្គការជាតិ និងអន្តរជាតិ | រាជធានី ខេត្ត | | X | | X |

## អាទិភាពមុខងារដែលស្នើឡើងដើម្បីផ្ទេរជាដំណាក់កាល ២០១៥ -២០១៧

| ល.រ | មុខងារ ឬមុខងាររង | ដំណាក់កាល |
|---|---|---|
| ១ | ផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនរងគ្រោះនិងងាយរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ រងគ្រោះដោយគ្រោះ ធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុផ្សេងៗ | ២០១៦ |
| ២ | ស្រង់ទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះ | ២០១៦ |
| ៣ | ផ្តល់សេវាថែទាំកុមារកំព្រានិងកុមារងាយរងគ្រោះនៅក្នុងមណ្ឌល និងបង្រួបបង្រួមគ្រួសារ | ២០១៥ |
| ៤ | ផ្តល់សេវាថែទាំកុមារកំព្រានិងកុមារងាយរងគ្រោះនៅក្នុងគ្រួសារ និងសហគមន៍ | ២០១៥ |
| ៥ | ចុះកិច្ចព្រមព្រៀងគម្រោងជាមួយអង្គការជាតិ និងអន្តរជាតិ | ២០១៥ |
| ៦ | ផ្តល់សេវាទប់ស្កាត់ និងការពារជនអនាថា | ២០១៦ |
| ៧ | ប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ | ២០១៦ |
| ៨ | ស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការនៅក្នុងមណ្ឌល និងតាមសហគមន៍ | ២០១៦ |
| ៩ | ជួយរៀបចំ និងបណ្តុះបណ្តាលក្រុមជួយខ្លួនឯងនៃជនពិការ | ២០១៦ |
| ១០ | ទប់ស្កាត់ និងការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ | ២០១៦ |
| ១១ | ស្តារនីតិសម្បទា និងធ្វើសមាហរណ កម្មអនីតិជនដែលប្រព្រឹត្តល្មើស | ២០១៧ |
| ១២ | ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មយុវជន និងកុមារដែលបានប្រើប្រាស់គ្រឿងញៀន | ២០១៧ |
| ១៣ | អភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ | ២០១៧ |
| ១៤ | ថែទាំមនុស្សចាស់តាមគ្រួសារ និងសហគមន៍ | ២០១៧ |
| ១៥ | ជម្រុញការអនុវត្ត និងពង្រឹងពង្រីកគម្រោងអភិវឌ្ឍអតីតយុទ្ធជននៅថ្នាក់ឃុំសង្កាត់ | ២០១៧ |
| ១៦ | ផ្តល់សម្បទានដីសង្គមកិច្ច និងសង់ផ្ទះជូនអតីតយុទ្ធជន | ២០១៧ |

## វិធីសាស្ត្រផ្ទេរមុខងារ



## 5. ការសាកល្បងផ្ទេរមុខងារនៅខេត្តបាត់ដំបង

២០១៥ គ.ជ.អ.ប និង UNICEF ផ្តល់ថវិកាឲ្យក្រសួង ស.អ.យ អនុវត្តសាកល្បងផ្ទេរមុខងារ ដែលមានផែនការដូចខាងក្រោម៖

១. រៀបចំផែនការផ្ទេរមុខងារ និងធនធានក្នុងដំណាក់កាលដំបូង

២. រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរមុខងារ និងធនធាន

៣. រៀបចំផែនការ ឯកសារ និងសម្ភារ សម្រាប់អភិវឌ្ឍសមត្ថភាព

<u>៤. រៀបចំវគ្គបណ្តុះបណ្តាល</u>

៥. រៀបចំវិធីសាស្ត្រដើម្បីសិក្សាវាយតម្លៃ

៦. អនុវត្តការសិក្សាវាយតម្លៃ និងរៀបចំរបាយការណ៍



### ផែនការផ្ទេរមុខងារសាកល្បង (ខេត្តបាត់ដំបង)

| ជំហាន | សកម្មភាពអនុវត្ត (២០១៥) |
|---|---|
| ១ | រៀបចំផែនការផ្ទេរមុខងារ និងធនធានក្នុងដំណាក់កាលដំបូង<br>• ពិនិត្យមុខងារដែលបានស្នើឡើងសម្រាប់ផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិភាក្សាជាមួយនាយកដ្ឋានសុខុមាលភាពកុមារ និងអង្គភាពពាក់ព័ន្ធ |
| ២ | រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរមុខងារ និងធនធាន<br>• ពិនិត្យមើលលិខិតបទដ្ឋានសម្រាប់ផ្ទេរមុខងារ(ថែទាំកុមារក្នុងមណ្ឌល&សហគមន៍)<br>• រៀបចំសិក្ខាសាលាដើម្បីរៀបចំប្រកាសរួម |
| ៣ | រៀបចំផែនការ ឯកសារ មេរៀននិងសម្ភារ សម្រាប់អភិវឌ្ឍសមត្ថភាព |
| ៤ | រៀបចំវគ្គបណ្តុះបណ្តាល<br>• បណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់)<br>• មន្ត្រីមន្ទីរ ស.អ.យ ខេត្តបាត់ដំបង |
| ៥ | រៀបចំវិធីសាស្ត្រដើម្បីសិក្សាវាយតម្លៃ<br>• ពិភាក្សាដើម្បីវិធីសាស្ត្រ/ស្តង់ដារវាយតម្លៃលើការអនុវត្តសាកល្បង<br>• ចុះសាកល្បងវិធីសាស្ត្រវាយតម្លៃដើម្បីកែលម្អ |
| ៦ | អនុវត្តការសិក្សាវាយតម្លៃ និងរៀបចំរបាយការណ៍<br>• វាយតម្លៃពីការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ត្រួតពិនិត្យរបាយការណ៍ដើម្បីត្រៀមពង្រីកការផ្ទេរមុខងារទាំងពីរជាអចិន្ត្រៃយ៍ |